## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

លេខ ០០២ សរ.សហវ

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៩

# សារាចរណែនាំ
# ស្តីពី
# ការផ្អាកបៀវត្សចំពោះ
# មន្ត្រីរាជការដែលមិនគោរពវិន័យការងារ

អ្នករាជការក្របខណ្ឌទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ដែលបានចូលធ្វើការនៅតាមក្រសួង ស្ថាប័ននានាមានសិទ្ធិទទួលប្រាក់បៀវត្សប្រចាំខែជាទៀងរាល់ខែ ដោយត្រូវអនុវត្តតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ។

ប៉ុន្តែកន្លងមក ជាការកត់សម្គាល់ មានមន្ត្រីរាជការខ្លះមិនបានបំពេញកាតព្វកិច្ចឱ្យបានត្រឹមត្រូវតាមច្បាប់ជាធរមាន ដូចជា មិនមកធ្វើការដោយគ្មានការអនុញ្ញាតជាមុនពីថ្នាក់ដឹកនាំរបស់ខ្លួន ឬដោយគ្មានមូលហេតុត្រឹមត្រូវ ឬយកម៉ោងរដ្ឋបាលទៅប្រកបមុខរបរផ្ទាល់ខ្លួនផ្សេងៗទៀត ឬប្រកបមុខរបរបន្ថែមត្រួតលើមុខងាររបស់ខ្លួនជាអ្នករាជការ ឬបានបំពានផ្សេងៗទៀតលើកាតព្វកិច្ចដែលផ្ទុយនឹងមាត្រាទី ៣៣ ៣៤ ៣៥ ៣៧ ៣៨ និង៣៩ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ហើយបាននៅត្រូវទទួលប្រាក់បៀវត្សជាធម្មតា។

ដើម្បីអនុវត្តការងារបើកផ្តល់តណទានបៀវត្សឱ្យបានត្រឹមត្រូវតាមល័ក្ខការណ៍ហិរញ្ញវត្ថុ និងគ្រប់គ្រងមន្ត្រីរាជការឱ្យបានហ្មត់ចត់តាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៧ ចំពោះមន្ត្រីរាជការដែលបានបំពានកាតព្វកិច្ចដូចខាងលើ ក៏ដូចជាការជម្រះឱ្យបានអស់នូវមន្ត្រីដែលមានតែឈ្មោះក្នុងបញ្ជីខ្មោច មន្ត្រីដែលគ្រាន់តែមកបង្ហាញខ្លួនរួចចេញទៅវិញបាត់ មន្ត្រីម្នាក់ឯងមានឈ្មោះពីរ មន្ត្រីស៊ីឈ្មោះគេ និងមន្ត្រីដែលប្រព្រឹត្តការក្លែងបន្លំលិខិតដោយទិញឈ្មោះគេ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមធ្វើការណែនាំដូចខាងក្រោម ៖

១. ចំពោះមន្ត្រីណាដែលឈប់ធ្វើការដោយគ្មានការអនុញ្ញាត ឬដោយគ្មានមូលហេតុត្រឹមត្រូវ ឬបានបំពានលើកាតព្វកិច្ចដែលផ្ទុយនឹងមាត្រាទី ៣៣ ៣៤ ៣៥ ៣៧ ៣៨ និង៣៩ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ហើយនៅមានឈ្មោះទទួលបើកប្រាក់បៀវត្សទៀងរាល់ខែនោះ ត្រូវដាក់ពិន័យដោយផ្អាកការងារ ឬលុបឈ្មោះចេញពីក្របខណ្ឌមន្ត្រីរាជការ ហើយប្រមូលប្រាក់មកវិញ រួចបង់ចូលថវិការដ្ឋទាំងអស់។

សហការរៀបចំដោយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងកម្មវិធីកំណែទម្រង់រដ្ឋបាល និងវិមជ្ឈការ (GIZ)-ចម្លងខ្លឹមសារទាំងស្រុងតាមច្បាប់ដើម

២. ចំពោះមន្ត្រីដែលមានតែឈ្មោះក្នុងបញ្ជីខ្មោច ត្រូវជម្រះ និងលុបឈ្មោះចោលឱ្យអស់ពីក្នុងបញ្ជីក្របខណ្ឌ រួចប្រមូលប្រាក់មកវិញ រួចបង់ចូលថវិការដ្ឋទាំងអស់។

៣. ចំពោះមន្ត្រីម្នាក់ឯងមានឈ្មោះពីរ មន្ត្រីស៊ីឈ្មោះគេ និងមន្ត្រីដែលប្រព្រឹត្តការក្លែងបន្លំលិខិតដោយទិញឈ្មោះគេ ដើម្បីចូលបម្រើការងារក្នុងក្របខណ្ឌ ត្រូវលុបឈ្មោះចេញពីក្របខណ្ឌ និងរៀបចំសំណុំរឿងផ្ញើជូនក្រសួងមានសមត្ថកិច្ចដើម្បីពិនិត្យ និងសម្រេចផ្តន្ទាទោសតាមច្បាប់។

៤. ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៩ តទៅ រាល់សំណើសុំបៀវត្សត្រូវដកចេញឱ្យស្រេចជាមុននូវមន្ត្រីរាជការណាដែលបានបំពានដូចក្នុងចំណុចទាំងបីខាងលើ។

ដើម្បីមានតម្លាភាព និងសមធមិចំពោះមន្ត្រីរាជការទូទៅ ខ្ញុំសង្ឃឹមថា ព្រះអង្គម្ចាស់ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ព្រមទាំងប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ក្រុងកែប ក្រុងប៉ៃលិន និងគ្រប់អភិបាលខេត្ត ក្រុងទូទាំងប្រទេស ច្បាស់ជាយកចិត្តទុកដាក់អនុវត្តខ្លឹមសារច្បាប់ដូចមានខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់ជាមិនខាន។

សារាចរនេះ មានអនុភាពគតិយុទ្ធចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន :**

- ខុទ្ទកាល័យព្រះមហាក្សត្រ
- ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណកម្មាធិការ គ.ជ.ប
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ
- ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងកែប
- ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងប៉ៃលិន
- គ្រប់ខេត្ត-ក្រុង
- ខុទ្ទកាល័យ សហវ
- គ្រប់អង្គភាពចំណុះ សហវ
- ឯកសារ និងកាលប្បវត្តិ